*ព័ត៌មានសម្រាប់សហគមន៍ពហុវប្បធម៌*

# *មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តសហគមន៍វប្បធម៌ចម្រុះ រដ្ឋឃ្វីនស្លែន (QTMHC)*

សេវាកម្មផ្គត់ផ្គង់ការញៀន និងសុខភាពផ្លូវចិត្ត Metro South (MSAMHS)

**តើយើងខ្ញុំជានរណា៖**

យើងខ្ញុំគឺជាសេវាកម្មអ្នកឯកទេសទូទាំងរដ្ឋ ដែលធ្វើការដើម្បីធានាថាមនុស្សមកពីសាវតាវប្បធម៌ខុសៗគ្នាទទួលបានការថែទាំសុខភាពផ្លូវចិត្ត និងការគាំទ្រត្រឹមត្រូវ ហើយថាសេវាកម្មដែលពួកគេទទួលបាន ឆ្លើយតបទៅនឹងតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ។

**តម្លៃ៖**

ពុំមានការចំណាយទេ។

**តំបន់ដែលគ្របដណ្តប់៖**

គ្រប់តំបន់ទាំងអស់នៅរដ្ឋឃ្វីនស្លែន

**តើយើងខ្ញុំធ្វើការជាមួយអ្នកណា៖**

- មនុស្សមកពីសាវតាវប្បធម៌ និងភាសាផ្សេងៗ
- មនុស្សគ្រប់វ័យ
- មនុស្សដែលជួបប្រទះនឹងបញ្ហាផ្លូវអារម្មណ៍ សង្គម ឬផ្លូវចិត្ត
- សមាជិកគ្រួសារនៃមនុស្សដែលមានបញ្ហាសុខភាពផ្លូវចិត្ត ហើយកំពុងទទួលបានការថែទាំ និងការផ្គត់ផ្គង់សុខភាពផ្លូវចិត្ត
- អ្នកផ្តល់សេវាកម្មដែលពាក់ព័ន្ធនឹងការថែទាំ និងការព្យាបាលមនុស្សដែលមានបញ្ហាសុខភាពផ្លូវចិត្ត
- ក្រុមសហគមន៍វប្បធម៌ ដើម្បីជួយបង្កើនការយល់ដឹងអំពីសុខភាពផ្លូវចិត្ត និងសុខុមាលភាព ហើយនិងសេវាកម្មទាំងឡាយដែលអាចរកបាន។

**ការយល់ព្រម៖**

ត្រូវទទួលបានការយល់ព្រមពីបុគ្គលដែលមានបញ្ហាសុខភាពផ្លូវចិត្ត ដើម្បីឱ្យយើងខ្ញុំអាចធ្វើការដោយផ្ទាល់ជាមួយបុគ្គលនោះ។ ការអនុញ្ញាតពីបុគ្គលក៏ចាំបាច់ផងដែរ ប្រសិនបើយើងខ្ញុំត្រូវបានស្នើសុំឱ្យធ្វើការជាមួយសមាជិកគ្រួសារ។ ប្រសិនបើបុគ្គលនោះប្រឈមនឹងគ្រោះថ្នាក់ដល់ខ្លួនឯង ឬអ្នកដទៃ ការវាយតម្លៃអាចផ្តល់ជូនដោយគ្មានការយល់ព្រម តាមរយៈច្បាប់សុខភាពផ្លូវចិត្តឆ្នាំ២០១៦។

### កិច្ចការទាំងឡាយដែលយើងខ្ញុំធ្វើ៖

- យើងខ្ញុំស្វែងរកដើម្បីឱ្យបានយល់ដឹងអំពីការបំភ្លឺខាងវប្បធម៌ (រាប់បញ្ចូលទាំងសាសនា) និងឥទ្ធិពលនៃវប្បធម៌លើបញ្ហាសុខភាពផ្លូវចិត្ត។ ការនេះជួយដល់គ្រូពេទ្យសុខភាពផ្លូវចិត្ត នៅពេលធ្វើការសម្រេចចិត្តអំពីការព្យាបាល និងការថែទាំ។
- យើងខ្ញុំផ្ដល់ជូនព័ត៌មានអំពីសុខភាពផ្លូវចិត្តដល់បុគ្គលម្នាក់ៗផ្ទាល់ និងសមាជិកគ្រួសារ ដើម្បីជួយឱ្យពួកគេបានយល់ដឹងកាន់តែច្បាស់អំពីជំងឺរបស់ពួកគេ និងវិធីលៃលកដោះស្រាយ។
- យើងខ្ញុំបណ្ដុះបណ្ដាល និងជួយអ្នកស្ម័គ្រចិត្តក្នុងក្រុមសហគមន៍វប្បធម៌ ដើម្បីជួយដោះស្រាយការមាក់ងាយអំពីជំងឺផ្លូវចិត្ត និងការសម្លាប់ខ្លួនឯង បង្កើនជំនាញដើម្បីដោះស្រាយភាពតានតឹងនៃការសម្របសម្រួលទៅនឹងវប្បធម៌ថ្មី ហើយបង្កើនចំណេះដឹងអំពីសេវាកម្មសុខភាពផ្លូវចិត្ត។
- យើងខ្ញុំចាត់ចែងវគ្គអប់រំសហគមន៍ស្ដីពីជំងឺផ្លូវចិត្ត និងប្រធានបទសុខុមាលភាព ឧទាហរណ៍ អំពីរបៀបដែលមេដឹកនាំសហគមន៍អាចជួយភ្ជាប់មនុស្ស ទៅនឹងសេវាកម្មឱ្យបានកាន់តែប្រសើរឡើង ។
- យើងខ្ញុំបង្កើត និងចែកចាយព័ត៌មានអំពីសុខភាពផ្លូវចិត្ត និងសុខុមាលភាពនៅក្នុងភាសាជាច្រើន។

### តើអ្វីដែលធ្វើឱ្យយើងខ្ញុំមានការយល់ដឹង និងឆ្លើយតបទៅនឹងវប្បធម៌?

យើងខ្ញុំមានអ្នកធ្វើការដែលមានពីវប្បធម៌ មកពីជាង១៦០ក្រុមវប្បធម៌ និងភាសាផ្សេងៗគ្នា។ យើងខ្ញុំភ្ជាប់អ្នកធ្វើការទាំងនេះទៅអ្នកផ្ដល់សេវាកម្មសុខភាពផ្លូវចិត្ត ដូច្នេះពួកគេអាចជួយដើម្បីជូនព័ត៌មានអំពីការថែទាំសុខភាពផ្លូវចិត្ត។

### ទាក់ទងមកយើងខ្ញុំ៖

*នរណាម្នាក់អាចបញ្ជូនទៅ QTMHC (រួមមានបុគ្គលផ្ទាល់ សមាជិកគ្រួសារ ឬអ្នកផ្ដល់សេវាកម្ម)*

ទូរស័ព្ទ: (07) 3317 1234 ឬ 1800 188 189 (នៅខាងក្រៅតំបន់ជុំវិញទីក្រុង Brisbane)

ម៉ោងធ្វើការ៖ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង៨.៣០ព្រឹក ដល់ម៉ោង៤.៣០ល្ងាច

អាសយដ្ឋាន៖ ជាន់ទី២ 228 Logan Road Woolloongabba QLD 4102

អ៊ីម៉ែល៖ QTMHC@health.qld.gov.au

វ៉ិបសៃថ៍៖ https://metrosouth.health.qld.gov.au/qtmhc